# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យឆ្លងព្រះវិហារសន្តយ៉ូសែបពោធិ៍ធំ
# ថ្ងៃទី១៨ កុម្ភៈ ២០១៧

អត្ថបទទី១៖ លវ ១៩,១-២.១៧-១៨
អត្ថបទទី២៖ ១ករ ៣,១៦-២៣
ដំណឹងល្អ៖ មថ ៥,៣៨-៤៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងមានអំណរសប្បាយ ដោយសារព្រះសហគមន៍បានទទួលព្រះវិហារថ្មីនៅពោធិ៍ធំនេះ។ វាជាពេលវេលាមួយដើម្បីកោតសរសើរព្រះជាម្ចាស់ និងអរព្រះគុណព្រះជាម្ចាស់ដែលថែរក្សាយើង ដែលស្រឡាញ់យើង។ យើងជាហ្វូងចៀមរបស់ព្រះអង្គយ៉ាងតូចមួយ ពេលយើងមានព្រះវិហារថ្មីនេះណែនាំឲ្យយើងត្រេកអរ ដោយអរព្រះគុណព្រះជាម្ចាស់ដែលបានណែនាំព្រះសហគមន៍យើងតាំងពីដើមរៀងមក។ ពេលយើងមានទាំងព្រះវិហារនិងមណ្ឌលសកម្មភាពថ្មីនេះ យើងសង្ឃឹមថាយើងអាចមានសកម្មភាពយ៉ាងច្រើន ដើម្បីប្រកាសដំណឹងល្អ។ ប៉ុន្មានថ្ងៃមុនខ្ញុំបានទៅជួបជាមួយសម្តេចប៉ាប រួមជាមួយក្រុមលោកអភិបាលកម្ពុជា-ឡាវ ពេលយើងផ្តល់សក្ខីភាពអំពីព្រះសហគមន៍របស់យើងនៅប្រទេសកម្ពុជានិងប្រទេសឡាវ បានធ្វើឲ្យសម្តេចប៉ាបភ្ញាក់ ដោយសារសម្តេចប៉ាបធ្លាប់ជួបជាមួយលោកអភិបាលដែលមកពីព្រះសហគមន៍មានគ្រីស្តបរិស័ទច្រើនដែលមានប្រវត្តិសាស្ត្រយ៉ាងយូរ ដែលមានអគារយ៉ាងច្រើន ពេលយើងផ្តល់សក្ខីភាពអំពីព្រះសហគមន៍តូចៗរបស់យើងសម្តេចប៉ាបបានរំភើបម៉ែនទែន។ សម្តេចប៉ាបបានមានប្រសាសន៍ថា **"ព្រះសហគមន៍តូចជាកម្លាំងមួយយ៉ាងពិសេស សម្រាប់ព្រះសហគមន៍ទាំងមូល"** ព្រះសហគមន៍តូចដែកតស៊ូ ព្រះសហគមន៍តូចដែលមានមរណសាក្សី ព្រះសហគមន៍តូចដែលមានគ្រីស្តបរិស័ទតិច ព្រះសហគមន៍តូចដែលឥតមានរចនាសម្ព័ន្ធអស្ចារ្យ ជាកម្លាំងរបស់ព្រះសហគមន៍សកលនៅក្នុងពិភពលោកទាំងមូល។ ពេលនោះសម្តេចប៉ាបកំពុងនិយាយដល់យើងតែម្តង ពេលខ្ញុំមកប្រទានពរដល់ព្រះសហគមន៍យើងនៅទីនេះ យើងត្រូវតែអរព្រះគុណព្រះជាម្ចាស់ដែលកំពុងថែរក្សាហ្វូងចៀមដ៏តូចរបស់យើង។ នៅពោធិ៍ធំនេះមិនមែនជាព្រះសហគមន៍ថ្មីទេ ជាព្រះសហគមន៍ចាស់មួយនៅក្នុងភូមិភាគភ្នំពេញមានអាយុប្រហែល១០០ឆ្នាំកន្លងមកហើយ។ ប៉ុន្តែជាព្រះសហគមន៍ដែលខ្សោយម្យ៉ាង មិនមែនជាព្រះសហគមន៍ដែលមានគ្រីស្តបរិស័ទរាប់ពាន់នាក់ តែនៅក្នុងព្រះសហគមន៍នេះយើងជឿថា នេះជាព្រះសហគមន៍ដែលមានកម្លាំងកាយកម្លាំងចិត្ត។ ដូចយើងបានស្តាប់ថា **"បងប្អូនជាសំណង់ដែលព្រះជាម្ចាស់កំពុងសង់"** ទោះបីថ្ងៃនេះយើងកំពុងសុំព្រះជាម្ចាស់ប្រទានពរលើព្រះវិហារថ្មី យើងសូមព្រះជាម្ចាស់ប្រទានពរលើព្រះសហគមន៍ មានន័យថាសម្រាប់បងប្អូនទាំងអស់ដែលនៅលើទឹកដីនេះ ដើម្បីធ្វើជាសាវ័កក្នុងការប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់។ ខ្ញុំបានបាចទឹកព្រះពរដល់បងប្អូន

ទាំងអស់ដែលមកចូលរួមពិធីបុណ្យនេះ ដើម្បីយល់ថាពិតមែនមែនយើងជាសំណង់ដែលព្រះជាម្ចាស់កំពុងសង់ ដែលយើងត្រូវការទុកនៅក្នុងចិត្តគំនិតរបស់យើង។ **ត្បិតគ្មាននរណាអាចចាក់គ្រឹះមួយផ្សេងៗ ក្រៅពីគ្រឹះដែលបានចាក់រួចហើយនោះទេ ពោលគឺព្រះយេស៊ូគ្រីស្ទ**។ ព្រះសហគមន៍នេះមានអាយុច្រើនដោយសារព្រះយេស៊ូគ្រីស្ទបានចាក់គ្រឹះ ការងារសំណង់ដែលយូរបំផុតគឺចាក់គ្រឹះតែម្តង។ ប៉ុន្មានឆ្នាំកន្លងមក ព្រះជាម្ចាស់បានចាក់គ្រឹះនៅទីនេះដែលមើកមិនសូវឃើញ ក្រោយមកមានជញ្ជាំងជាបងប្អូនគ្រីស្ទបរិស័ទនៅទីនេះនិងនៅក្តីកណ្តាល ក្រោយមកទៀតយើងត្រូវការពេលយ៉ាងច្រើនដើម្បីលាបថ្នាំ ដើម្បីតុបតែងឲ្យស្អាត ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជារូបរាងរបស់ព្រះជាម្ចាស់។ សម្រាប់ជីវិតរបស់យើងជាគ្រីស្ទបរិស័ទ យើងត្រូវការពេលច្រើនដើម្បីកែប្រែចិត្តគំនិត ដើម្បីទទូលទទួលជីវិតថ្មីតាមរយៈអគ្គសញ្ញាជ្រមុជទឹកដែលយើងបានទទួល ដើម្បីផ្លាល់សក្ខីភាពអំពីព្រះជាម្ចាស់ដែលជាធម៌មេត្តាករុណា ដើម្បីតុបតែងជីវិតរបស់យើងតាមរបៀបរបស់ព្រះជាម្ចាស់។ បន្តិចម្តងៗ យើងលាបថ្នាំនៃសេចក្តីស្រឡាញ់ បន្តិចម្តងៗយើងដាំផ្កានៃធម៌មេត្តាករុណា បន្តិចម្តងៗយើងថែមថ្នាំនៃការលើកលែងទោស នេះណែនាំឲ្យព្រះសហគមន៍របស់យើងអាចចេញរូបរាងរបស់ព្រះជាម្ចាស់។ ព្រះសហគមន៍នេះយើងមានព្រះវិហារប្រាំរួចមកហើយ ដោយសារមានបីនៅក្នុងទន្លេមេគង្គ តែអ្វីដែលសំខាន់ឲ្យបងប្អូនថែរក្សាជំនឿ ដែលយើងបានទទួលពីព្រះជាម្ចាស់ដើម្បីរស់នៅក្នុងជីវិតរបស់ព្រះជាម្ចាស់។ យើងតុបតែងជីវិតរបស់យើងដូចយើងបានតុបតែងព្រះវិហារនេះ ប្រសិនបើយើងយកចិត្តទុកដាក់អធិដ្ឋាន។ ព្រះវិហារដែលយើងបានសាងសង់នៅទីនេះទៅជាកន្លែងមួយដែលយើងអាចចេញចូលរាល់ថ្ងៃ ដោយដឹងថាយើងមានទូព្រះកាយជាវត្តមានរបស់ព្រះគ្រីស្ទ ព្រះគ្រីស្ទរង់ចាំយើងមកសួរសុខទុក្ខព្រះអង្គ។ ព្រះវិហារនេះខ្ញុំនឹងដាក់ធាតុរបស់អ្នកម្តាយតេរេសា ជីវិតរបស់អ្នកម្តាយតេរេសាគឺអធិដ្ឋាន ភ្ជាប់ជាមួយព្រះយេស៊ូមួយថ្ងៃពីរបីម៉ោងអធិដ្ឋាននៅមុខទូរព្រះកាយ ដើម្បីទូលអង្វរព្រះអង្គប្រទានកម្លាំង ប្រទានជំនឿរឹងមាំ ប្រទានចិត្តមេត្តាករុណា ដើម្បីបម្រើអ្នកក្រីក្របម្រើអ្នកជំងឺបម្រើអ្នកតូចតាច។ សម្រាប់ព្រះសហគមន៍របស់យើង ដែលមានសន្តសិលាដែលជាគ្រីស្ទទូតដំបូង និងជាឧបការី ដែលមានអ្នកម្តាយតេរេសានៅក្នុងអាសនៈដើម្បីការពារថែរក្សាយើង ល្មមហើយឲ្យព្រះសហគមន៍របស់យើងមានរូបរាងដូចព្រះជាម្ចាស់។ ខ្ញុំសប្បាយចិត្តដែលបងប្រុសបងស្រីជម្រុញឲ្យខ្ញុំទទួលបានធាតុរបស់អ្នកម្តាយតេរេសា ពេលខ្ញុំដល់ទីក្រុងរ៉ូមគេបានឲ្យធាតុអ្នកម្តាយតេរេសាពីរមួយសម្រាប់ពោធិ៍ធំ មួយសម្រាប់ព្រែកប្បាស់។ ខ្ញុំចង់បានមួយសម្រាប់ទុកនៅផ្ទះរបស់ខ្ញុំប៉ុន្តែមិនហ៊ានប្រាប់គេ តែពេលខ្ញុំមកដល់ភ្នំពេញវិញខ្ញុំបានទទួលធាតុអ្នកម្តាយតេរេសាពីរថែមទៀត នេះអ្នកម្តាយតេរេសាបានការពារថែរក្សាយើងពិតមែន។ ណេះជាសញ្ញាមួយយ៉ាងពិសេស ដោយអធិដ្ឋានដូចម្តាយតេរេសាដើម្បីការពារថែរក្សាជំនឿ

របស់យើង និងដើម្បីមានកម្លាំងឲ្យព្រះសហគមន៍តូចរបស់យើង ទៅជាកម្លាំងសម្រាប់ព្រះសហគមន៍ក្នុងពិភពលោកទាំងមូល។

ហេតុនេះហើយ យើងត្រូវការធ្វើដូចម្តេចដើម្បីណែនាំឲ្យព្រះជាម្ចាស់មានព្រះហឫទ័យសប្បាយដោយសារយើង កុំឲ្យព្រះអង្គព្រួយព្រះហឫទ័យដោយសារយើង។ យើងបានស្តាប់ "**នៅតាមមាត់ស្ទឹងទាំងសងខាងមានដើមឈើហូបផ្លែគ្រប់មុខដុះ ស្លឹកវាមិនចេះស្រពោនឡើយ ហើយផ្លែក៏មិនចេះអស់ដែរ ជារៀងរាល់ខែដើមឈើទាំងអស់នោះផ្តល់ផ្លែថ្មីៗមិនចេះដាច់**"។ សម្រាប់បងប្អូនដែលនៅកន្លែងដែលមានដើមស្វាយយ៉ាងច្រើនមានន័យណាស់ នៅទីនេះយើងមានរបៀបដើម្បីមានផ្លែជារៀងរាល់ខែដោយបង្ខំឲ្យមានផ្លែខុសរដូវ គឺបាញ់ថ្នាំគីមីដោយណែនាំឲ្យបន្តិចម្តងៗដើមស្វាយឆាប់ងាយនិងផ្លែគ្មានរស់ជាតិឆ្ងាញ់។ សម្រាប់ជីវិតរបស់យើង កុំឲ្យយើងធ្វើជាដើមស្វាយដែលបាញ់ថ្នាំគីមី ផ្ទុយទៅវិញឲ្យព្រះវិហារនេះទៅជាព្រះសហគមន៍ដែលមានផ្លែថ្មីៗជារៀងរាល់ខែដោយនឹកឃើញថាកន្លែងនេះជាទឹកដីរបស់មរណសាក្សី ជាកន្លែងដែលឆ្មារសាឡាស់បានកើត ជាកន្លែងដែលឆ្មារសាឡឹមបានរស់នៅ ជាកន្លែងដែលឆ្មារសាឡាស់និងឆ្មារសាឡឹមបានប្រើជីវិតជាបូជាចារ្យនៅទីនេះ។ យើងអាចនិយាយថា ទោះបីឈាមរបស់មរណសាក្សីមិនបានហូរលើទឹកដីនេះប៉ុន្តែពូជនៃមរណសាក្សីបានចេញពីព្រះសហគមន៍នេះ។ ដោយបានណែនាំឲ្យព្រះសហគមន៍របស់យើងមានបូជាចារ្យ មានលោកអភិបាល មានមរណសាក្សីពូជនៃមរណសាក្សីជាពូជគ្រីស្តបរិស័ទ។ សម្តេចប៉ាបបានរំលឹកថា យើងមានសំណាងដោយសារយើងមកពីទឹកដីដែលឈាមរបស់មរណសាក្សីបានហូរ និងឈាមរបស់មរណសាក្សីជាពូជនៃគ្រីស្តបរិស័ទ។ ពិតមែនយើងជាពូជ ដែលចេញពីមរណសាក្សី ដែលណែនាំឲ្យយើងមានកម្លាំងពិតមែន ដើម្បីបន្តបម្រើព្រះសហគមន៍អស់ពីកម្លាំងកាយកម្លាំងចិត្ត។ យើងមានលោកឪពុកលី ដែលបានកើតនៅទីនេះនិងមានបងប្អូនគាត់ផងដែរ ដែលបានណែនាំឲ្យព្រះសហគមន៍មានបូជាចារ្យម្នាក់ ដែលបម្រើព្រះសហគមន៍អស់ពីកម្លាំងកាយចិត្ត។ សន្តសិលា អញ្ជើញយើងឲ្យយើងផ្តល់សក្ខីភាពអំពីសេចក្តីសង្ឃឹមរបស់យើងជានិច្ច។ ខ្ញុំសង្ឃឹមថាកន្លែងនេះទៅជាកន្លែងដែលផ្តល់សក្ខីភាពអំពីសេចក្តីសង្ឃឹមផង និងជាកន្លែងមួយដែលត្រូវតែថ្លែងព្រះគម្ពីររបស់ព្រះជាម្ចាស់ ដូចជាសញ្ញាសម្គាល់នៃព្យាការីដើម្បីធ្វើដូចម្តេចឲ្យព្រះសហគមន៍នៅទីនេះរស់នៅជាបងប្អូន ដើម្បីរស់នៅជាព្រះសហគមន៍របស់ព្រះគ្រីស្តដែលជាធ្លុងតែមួយនៅក្នុងសេចក្តីស្រឡាញ់នៃព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះយេស៊ូមានព្រះបន្ទូលថា "**តាមពិតនៅក្នុងបីថ្ងៃ ព្រះយេស៊ូអាចសាងសង់ព្រះវិហារថ្មីវិញបាន**" ដោយសារព្រះសហគមន៍របស់ព្រះគ្រីស្តជាព្រះកាយរបស់ព្រះជាម្ចាស់។ ពេលយើងនិយាយអំពីព្រះកាយរបស់ព្រះគ្រីស្ត យើងគិតអំពីព្រះកាយដែលរងទុក្ខលំបាក អំពីព្រះកាយដែលអំណរ អំពីពញរះកាយដែលសម្តែងសេរីរុងរឿងរបស់ព្រះជាម្ចាស់។ ដូច្នេះជីវិតរបស់យើងមានទុក្ខលំបាកផង យើងមានអំណរសប្បាយ

ផង យើងមានសេរីរុងរឿងរបស់ព្រះអង្គដែលណែនាំឲ្យយើងទៅជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គនេះណែនាំឲ្យយើងយល់ថា ពិតមែនយើងជាព្រះសហគមន៍របស់ព្រះគ្រីស្ត។ កុំឲ្យយើងខ្លាចលីឈើឆ្កាងរបស់យើង យើងត្រូវការយកចិត្តទុកដាក់ថែមទៀតរួមជាមួយបងប្អូនគ្រីស្តបរិស័ទនៅទីនេះដើម្បីកសាងព្រះសហគមន៍យើងដែលផ្តល់សក្ខីភាព។ យើងត្រូវតស៊ូថែមទៀតរួមជាមួយគ្នា ដោយយកចិត្តទុកដាក់តាមរយៈគណកម្មការនីមួយៗគណកម្មការប្រកាសដំណឹងល្អ គណកម្មការរៀបចំពិធីបុណ្យ គណកម្មការសង្គហ ដោយដឹងថាទោះយើងមិនមែនជាគណកម្មការក៏ដោយយើងជាគ្រីស្តបរិស័ទព្រះសហគមន៍នេះជាព្រះសហគមន៍របស់យើង។ យើងធ្វើដូចម្តេចដើម្បីឲ្យព្រះសហគមន៍នេះមានជីវិតរួមជាមួយលោកឪពុកដែលជាគ្រូគង្វាល រួមគ្នាយើងកសាងព្រះសហគមន៍របស់ព្រះគ្រីស្ត។ ព្រះសហគមន៍ដែលរងទុក្ខលំបាកពិតមែន ប៉ុន្តែព្រះសហគមន៍ដែលផ្តល់សក្ខីភាពអំពីអំណរសប្បាយនិងទទួលសេរីរុងរឿងរបស់ព្រះជាម្ចាស់ ដើម្បីឲ្យយើងរួមគ្នាទៅជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ។

ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់ព្រះសហគមន៍ថ្មីយើងយកចិត្តទុកដាក់ ដើម្បីធ្វើដូចម្តេចជារៀងរាល់ថ្ងៃដើមឈើទាំងអស់ផ្តល់ផ្លែថ្មី ដែលមិនចេះដាច់។ យើងទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរឲ្យយើងទាំងអស់ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាព្រះសហគមន៍ដែលមានជីវិត។ អាម៉ែន។